សមាគមធនាគារនៅកម្ពុជា
THE ASSOCIATION OF BANKS IN CAMBODIA

សមាគមមីក្រូហិរញ្ញវត្ថុកម្ពុជា
Cambodia Microfinance Association

សមាគមសហព័ន្ធហិរញ្ញវត្ថុ និងបច្ចេកវិទ្យានៃកម្ពុជា
CAMBODIAN ASSOCIATION OF FINANCE & TECHNOLOGY

# សេចក្តីថ្លែងការណ៍រួម

សមាគមធនាគារនៅកម្ពុជា សមាគមមីក្រូហិរញ្ញវត្ថុកម្ពុជា និងសមាគមសហព័ន្ធហិរញ្ញវត្ថុ និងបច្ចេកវិទ្យានៃកម្ពុជា បានដឹងអំពីផ្លែតហ្វមទាក់ទងនឹងរូបិយវត្ថុគ្រីបតូមួយចំនួន ជាពិសេស PAYEER ដែលបានប្រើប្រាស់ឈ្មោះគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ ដែលជាសមាជិករបស់សមាគមទាំងបី ដោយគ្មានការអនុញ្ញាត និងបានផ្សព្វផ្សាយពីកិច្ចសហការជាមួយគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុនៅកម្ពុជាមួយចំនួន ក្នុងការទូទាត់ការដាក់ប្រាក់ និង ដកប្រាក់លើការវិនិយោគ និងការជួញដូរលើរូបិយវត្ថុគ្រីបតូរួមមាន Bitcoin, Ethereum និង កាបូប Crypto ជាដើម ។

សមាគមទាំងបី ព្រមទាំងសមាជិករបស់ខ្លួនទាំងអស់ សូមធ្វើការបដិសេធចំពោះការផ្សព្វផ្សាយនេះ និងប្រកាសមិនជាប់ពាក់ព័ន្ធទៅនឹងក្រុមហ៊ុន PAYEER ឬមានកិច្ចសហប្រតិបត្តិការលើការទូទាត់ ឬការជួញដូរលើប្រភេទរូបិយវត្ថុគ្រីបតូឡើយ។ សមាគមទាំងបី សូមធ្វើការក្រើនរំលឹកដល់សាធារណជនថា ការធ្វើប្រតិបត្តិការលើរូបិយវត្ថុគ្រីបតូ (Crypto) រួមមានមាន Bitcoin, Ethereum និង កាបូប Crypto ជាដើម មិនបានទទួលស្គាល់ជាផ្លូវការទេនៅកម្ពុជា សូមសាធារណជនមេត្តាប្រុងប្រយ័ត្នរាល់ប្រតិបត្តិការ និងសកម្មភាពទាំងអស់នេះ ចៀសវាងធ្លាក់ក្នុងការបោកបញ្ឆោតអូសទាញវិនិយោគ ឬ ជួញដូរឧបករណ៍ហិរញ្ញវត្ថុនេះ ដែលមិនមានសុវត្ថិភាព និងអាចនឹងនាំឱ្យមានការខាតបង់។

សេចក្តីដូចបានជម្រាបជូនខាងលើ សូមសាធារណជនទាំងអស់មេត្តាជ្រាបជាព័ត៌មាន និង មានការប្រុងប្រយ័ត្នខ្ពស់ ។

ថ្ងៃសៅរ៍ ៤រោច ខែកត្តិក ឆ្នាំខាល ចត្វាស័ក ព.ស. ២៥៦៦

ភ្នំពេញ, ថ្ងៃទី១២ វិច្ឆិកា ឆ្នាំ២០២២

**សមាគមសហព័ន្ធហិរញ្ញវត្ថុ និងបច្ចេកវិទ្យានៃកម្ពុជា**

**សមាគមមីក្រូហិរញ្ញវត្ថុកម្ពុជា**

**សមាគមធនាគារនៅកម្ពុជា**